**សេចក្តីប្រកាសព័ត៌មានរួមរបស់**
**ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**
**អង្គការសុខភាពពិភពលោក**
**និងអង្គការសហប្រជាជាតិប្រយុទ្ធនឹងជំងឺអេដស៍**

UNAIDS

ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦

## ករណីឆ្លងមេរោគអេដស៍នៅឃុំសំបូរមាស ស្រុកមុខកំពូល ខេត្តកណ្តាល

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងដៃគូអភិវឌ្ឍន៍បានទទួលរបាយការណ៍ថាមានករណីឆ្លងមេរោគអេដស៍នៅឃុំសំបូរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ចំនួន១៨នាក់ ដែលបានឃើញចាប់ពីខែ មករា ឆ្នាំ២០១៦ កន្លងមក។ ផ្អែកតាមការបារម្ភនិងសំណូមពររបស់សហគមន៍ខាងលើ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ (NCHADS) សហការជាមួយមន្ទីរសុខាភិបាលខេត្តកណ្តាល អាជ្ញាធរដែនដី និងអង្គការមិនមែនរដ្ឋាភិបាល បានចុះសិក្សាស្រាវជ្រាវករណីខាងលើនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៦ ដោយបានផ្តល់សេវាប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់។ លទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថាក្នុងចំណោមប្រជាជនដែល ចូលរួមស្ម័គ្រចិត្តធ្វើតេស្តឈាមរកមេរោគេដស៍ ចំនួន២៧៨នាក់ (ស្ត្រី១៧១នាក់) មាន៨នាក់បានឆ្លងមេរោគអេដស៍។ ក្នុងចំណោមប្រជាជនដែលបានចូលរួមធ្វើតេស្តខាងលើមានកុមារចំនួន១១២នាក់ (កុមារីចំនួន៧០នាក់) ពុំមានឆ្លងមេរោគអេដស៍ទេ។

ក្រុមជំនាញរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ អង្គការសុខភាពពិភពលោក (WHO) អង្គការសហប្រជាជាតិប្រយុទ្ធនឹងជំងឺអេដស៍(UNAIDS) និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក(US-CDC)បានពិនិត្យ យ៉ាងម៉ត់ចត់នូវលទ្ធផលនៃការសិក្សាស្រាវជ្រាវដោយបាន ឯកភាពជារួមថា ការកើនឡើងនូវការ ចូលរួមធ្វើតេស្តឈាមរកមេរោគអេដស៍ របស់សហគមន៍ខាងលើនេះគឺដោយមានការយល់ដឹង និងការលើកទឹកចិត្តអោយចូលរួមធ្វើតេស្តរកមេរោគអេដស៍ដែលជាកត្តានាំអោយមានការកើន ឡើងនូវការរកឃើញករណីផ្ទុកមេរោគអេដស៍។ ទិន្នន័យនេះមិនបញ្ជាក់អំពីការបារម្ភនូវការឆ្លងរាលដាលមេរោគអេដស៍នោះទេ។ កត្តានេះបញ្ជាក់ពីសារៈសំខាន់នៃការកើនឡើងនូវការយល់ដឹងអំពីការ ធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ដែលជាមធ្យោបាយដ៏សំខាន់ ក្នុងការបង្កើនការរកឃើញអ្នកផ្ទុកមេរោគអេដស៍ដែលមិនទាន់ដឹងពីស្ថានភាពខ្លួនឯង។ ការលើកទឹកចិត្តដល់សហគមន៍អោយមកធ្វើតេស្តឈាមរកមេរោគអេដស៍នៅសេវាធ្វើតេស្តដែលទទួលស្គាល់ ដោយក្រសួងសុខាភិបាលគឺជាផ្នែកមួយនៃយុទ្ធសាស្ត្រជាតិក្នុងការបង្ការថែទាំព្យាបាលជំងឺអេដស៍។ ការឆាប់រកឃើញករណីឆ្លងមេរោគអេដស៍ នឹងជួយដល់ពួកគាត់អោយទទួលបាន សេវាការថែទាំ ព្យាបាលទាន់ពេលវេលា ដែលរួមចំណែកបង្កើនប្រសិទ្ធភាពនៃការព្យាបាលដោយឱសថប្រឆាំង មេរោគអេដស៍ ព្រមទាំងចូលរួមបង្ការការចំលងមេរោគអេដស៍ទៅអ្នកដទៃ។ យុទ្ធសាស្ត្រនេះ នឹងធ្វើអោយប្រសើរឡើងនូវសុខភាព និងគុណភាពនៃជីវិតរបស់អ្នកផ្ទុកមេរោគអេដស៍ ដែលរួមចំណែកក្នុងការសំរេចទិសដៅក្នុងការលុបបំបាត់ការឆ្លងថ្មី

នៃមេរោគអេដស៍នៅ ឆ្នាំ២០២៥។ ក្រសួងសុខាភិបាលសូមបញ្ជាក់ថា ការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ និងសេវាព្យាបាលជំងឺអេដស៍ប្រកបដោយគុណភាពគឺគ្មានការបង់ថ្លៃទេ។

" រាជរដ្ឋាភិបាលនឹងបន្តការខិតខំប្រឹងប្រែងដោយផ្តល់ការគាំទ្រដល់កម្មវិធីបង្ការ ថែទាំព្យាបាលជំងឺអេដស៍ ដោយបញ្ចៀសនូវការម៉ាក់ងាយ រើសអើងអ្នកផ្ទុកមេរោគអេដស៍។ ទន្ទឹមនឹងនេះ ក្រសួងសុខាភិបាល សូមលើកទឹកចិត្តដល់អ្នកដែលមានការប្រព្រឹត្តិប្រឈមមុខនឹងការឆ្លងមេរោគអេដស៍អោយទៅទទួលសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ និងសេវាថែទាំ ព្យាបាលជំងឺអេដស៍" ប្រសាសន៍របស់ ឯកឧត្តមវេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍នឹងបន្តការតាមដានដោយយកចិត្តទុកដាក់នូវសភាពការណ៍ខាងលើនេះ និងអំពាវនាវដល់សាធារណៈជនសូមគោរពនូវសិទ្ធិក្នុងការរក្សាការសំងាត់ និងភាពថ្លៃថ្នូររបស់អ្នកផ្ទុកមេរោគអេដស៍ ព្រមទាំងបញ្ចៀសនូវការម៉ាក់ងាយនិងការរើសអើងដល់ពួកគាត់។


សំរាប់ព័តមានបន្ថែមសូមទំនាក់ទំនង:

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ**

លោកវេជ្ជ. លី ពេញស៊ិន នាយកមជ្ឈមណ្ឌលជាតិ

លេខទូរស័ព្ទ: ០១២ ៨៥០ ០៥៣ សារអេឡិចត្រូនិច: penhsun@nchads.org

**អង្គការសុខភាពពិភពលោក**

លោកវេជ. Laurent Ferradini, HIV Team Leader

លេខទូរស័ព្ទ: ០១២ ៩០៥ ១៦១ សារអេឡិចត្រូនិច: ferradinil@who.int

**អង្គការសហប្រជាជាតិប្រយុទ្ធនឹងជំងឺអេដស៍**

លោកស្រី Marie-Odile Emond ប្រធានអង្គការ

លេខទូរស័ព្ទ: ០១២ ៩៩០ ៦៤៥

សារអេឡិចត្រូនិច: emondm@unaids.org

លោក Saleem Muhammad ទីប្រឹក្សាផ្នែកព័តមានយុទ្ធសាស្រ្ត

លេខទូរស័ព្ទ: ០៨៩ ៩៨០ ៩៥៧

សារអេឡិចត្រូនិច: saleemm@unaids.org


Sent from Messenger